ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែ បឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២១*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយលោកជំទាវ Victoria Kwakwa អនុប្រធានធនាគារពិភពលោក ប្រចាំតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក

នៅរសៀលថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២១, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលជួបលោកជំទាវ Victoria Kwakwa អនុប្រធានធនាគារពិភពលោក ប្រចាំតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក តាមរយៈប្រព័ន្ធ Video Conference ដើម្បីពិភាក្សាអំពីស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជា, ផែនការយុទ្ធសាស្ត្រនៃការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ និងលទ្ធភាពនៃការចូលរួមរបស់ធនាគារពិភពលោកក្នុងការគាំទ្ររាជរដ្ឋាភិបាលក្នុងកិច្ចខិតខំប្រឹងប្រែងស្តារសម្បទាសេដ្ឋកិច្ចឡើងវិញ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរ និងរឹងមាំ ជាមួយធនាគារពិភពលោក ក្នុងរយៈពេលជាងពីរទស្សវត្សរ៍កន្លងមក ដែលជាក់ស្តែង ឆ្លុះបញ្ចាំងច្បាស់តាមរយៈការចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងកាលៈទេសៈដ៏លំបាកលើកិច្ចការប្រយុទ្ធ និងគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ (COVID-19) ។ ក្នុងគោលដៅគ្រប់គ្រងការឆ្លងរាលដាលលក្ខណៈទ្រង់ទ្រាយធំ, រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ **"ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិ ចាក់វ៉ាក់សាំងកូវីដ-១៩ សំដៅបង្កើតឱ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ២០២១"** និងដាក់គោលដៅចាក់វ៉ាក់សាំងជូនប្រជាជនឱ្យបាន ១០ លាននាក់ ដែលតាមការប៉ាន់ស្មាន នឹងអាចសម្រេចបាននាខែ តុលា ឬ ខែ វិច្ឆិកា ឆ្នាំ ២០២១ ខាងមុខនេះ ។ ក្នុងទិសដៅនេះ, រាជរដ្ឋាភិបាលបានបុរេសកម្មក្នុងការទទួល និងបញ្ជាទិញវ៉ាក់សាំងដោយផ្ទាល់ពីអ្នកផលិតវ៉ាក់សាំង ដែលគិតត្រឹមថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២១ ទទួលបានវ៉ាក់សាំងសរុបប្រមាណ ៩ លានដូស ហើយប្រសិនបើមិនមានការប្រែប្រួលទេ កម្ពុជារំពឹងថានឹងទទួលបានវ៉ាក់សាំងដែលបានពីការបញ្ជាទិញ ចំនួន ១១ លានដូសបន្ថែមទៀតនៅត្រឹមខែ សីហា ឆ្នាំ ២០២១ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនអំពីវិធានការណ៍គោលនយោបាយមុតស្រួចរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញជាបន្តបន្ទាប់ចំនួន ៨ ជុំ សំដៅប្រយុទ្ធការពារសុខភាពអាយុជីវិតប្រជាជន រក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ជាពិសេសគ្រួសារក្រីក្រ និងងាយរងគ្រោះ ។ វិធានការជុំទី ៩ ស្តីពីការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងអំឡុង និងក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ ក៏នឹងត្រូវដាក់ចេញបន្ថែមទៀតក្នុងពេលឆាប់ៗខាងមុខនេះ ។ កញ្ចប់ចំណាយអន្តរាគមន៍ជាក់ស្តែងទាំងនោះរួមមាន÷ ១. ចំណាយលើការទប់ស្កាត់ និង

ព្យាបាលជំងឺកូវីដ-១៩ តាមរយៈក្រសួងសុខាភិបាល, ២. ចំណាយលើការបណ្តុះបណ្តាលជំនាញ និងឧបត្ថម្ភកម្មករពេលព្យួរកិច្ចសន្យាការងារ តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ៣. គម្រោងសាច់ប្រាក់ពលកម្មចំនួន ១០០ លានដុល្លារអាមេរិក នៅឆ្នាំ ២០២០ និង ១៦០ លានដុល្លារអាមេរិក នៅឆ្នាំ២០២១, ៤. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារ ក្រ-១ ក្រ-២ និង ជនងាយរងគ្រោះ, ៥. ចំណាយផ្នែកសន្តិសុខស្បៀង និងការជំរុញចលនាផលិតស្បៀង និងចំណាយផ្សេងៗ, និង ៦. ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ចជួយដល់សហគ្រាសធុនតូច និងមធ្យម តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារសហគ្រាសធុនតូច និងមធ្យម និងក្រុមហ៊ុនសាជីវកម្មធានាឥណទានកម្ពុជា ។

ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូន អំពីផែនការយុទ្ធសាស្ត្រនៃការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីកូវីឌ តាមរយៈអភិក្រមចំនួន ៣ រួមមាន÷ ១. ការស្តារ (Recovery) ផ្តោតទៅលើវិស័យសុខាភិបាល, ការផ្តល់ហិរញ្ញប្បទានដល់វិស័យឯកជន, គោលនយោបាយសារពើពន្ធ, វិស័យកសិកម្ម, វិស័យទេសចរណ៍, និងវិស័យកាត់ដេរ, ២. ការកែទម្រង់ (Reform) សំដៅលើការកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់កំណើន, ពិពិធកម្ម និងភាពប្រកួតប្រជែង, និង ៣. ភាពធន់ (Resiliency) ផ្តោតទៅលើវិស័យឌីជីថល, ការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម, ការអភិវឌ្ឍជំនាញ, ការស្តារសេដ្ឋកិច្ចឡើង វិញលក្ខណៈបៃតង, និងការពង្រឹងប្រព័ន្ធគាំពារសង្គម។

លោកជំទាវ Victoria Kwakwa បានថ្លែងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ និងគ្រប់គ្រងបញ្ហានៃវិបត្តិជំងឺកូវីដ-១៩ និងអបអរសាទរចំពោះភាពជោគជ័យរបស់រាជរដ្ឋាភិបាល ក្នុងការទទួល និងទិញវ៉ាក់សាំងបានគ្រប់គ្រាន់សម្រាប់ធានាការចាក់វ៉ាក់សាំងជូនប្រជាជនតាមគោលដៅក្នុងល្បឿនលឿន និងឆាប់រហ័ស ។ លោកជំទាវ ក៏បានវាយតម្លៃខ្ពស់ចំពោះផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ ឆ្នាំ ២០២១-២០២៣ ដែលមានលក្ខណៈច្បាស់លាស់ ប្រាកដនិយម និងគ្រប់ជ្រុងជ្រោយ ។ លោកជំទាវ បានបញ្ជាក់អំពីជំហរគាំទ្រយ៉ាងពេញទំហឹងរបស់ធនាគារពិភពលោក ក្នុងការរួមចំណែកគាំទ្ររាជរដ្ឋាភិបាល ក្នុងការអនុវត្តផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយ វិបត្តិកូវីដ-១៩ នេះ ដោយសន្យាពិនិត្យឡើងវិញ និងកែសម្រួលឯកសារក្របខ័ណ្ឌនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល ជាមួយធនាគារពិភពលោក (Country Partnership Framework 2019-2023) ឱ្យឆ្លើយតបទៅនឹងបរិការណ៍បច្ចុប្បន្ននៃជំងឺកូវីដ-១៩ និងស្របតាមផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ ឆ្នាំ២០២១-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្តងទៀត ចំពោះកិច្ចសហការដ៏ល្អ និងស្វាគមន៍ចំពោះការចូលរួមចំណែករបស់ធនាគារពិភពលោក ។